ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......១៤៩៥......អពដ

GENERAL DEPARTMENT OF TAXATION

# សេចក្តីថ្លែងការណ៍

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើសេចក្តីថ្លែងការណ៍ឆ្លើយតបនឹងការចុះផ្សាយរបស់សារព័ត៌មានក្នុងស្រុក ក៏ដូចជាការចុះផ្សាយនៅក្នុងគណនីបណ្តាញសង្គមពេញនិយមមួយចំនួន ដែលថ្មីៗនេះបានចុះផ្សាយបំផុសបំផុល បំពុលបរិយាកាស នូវព័ត៌មានទាក់ទិនទៅនឹងការផ្ទេរភារកិច្ចមន្ត្រីរាជការពន្ធដារនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ។

ចំពោះការផ្ទេរភារកិច្ចរបស់មន្ត្រីពន្ធដារសាខាពន្ធដារខណ្ឌចំការមន និងសាខាពន្ធដារខណ្ឌមួយចំនួនទៀត ក្នុងពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺជូនសាធារណជនគ្រប់មជ្ឈដ្ឋានឱ្យបានជ្រាបថា ការកែសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការដូចមានចែងក្នុងប្រកាសលេខ ២៣៩ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ថ្មីៗនេះ គឺធ្វើឡើងជាប្រក្រតី ដូចប្រកាសស្តីពីការតែងតាំង និងផ្ទេរភារកិច្ច ដែលបានធ្វើកន្លងមក ពោលគឺអគ្គនាយកដ្ឋានពន្ធដារតែងតែស្នើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការតែងតាំង ផ្លាស់ប្តូរ និងផ្ទេរភារកិច្ចរបស់មន្ត្រីពន្ធដារជាបន្តបន្ទាប់ ពីសាខាពន្ធដារខេត្តទៅសាខាពន្ធដារខណ្ឌ ឬពីសាខាពន្ធដារខណ្ឌទៅសាខាពន្ធដារខេត្ត ឬពីនាយកដ្ឋាន ទៅសាខាពន្ធដារខេត្ត-ខណ្ឌ ជាដើម ក្នុងបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង សំដៅធ្វើយ៉ាងណាធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

ម្យ៉ាងវិញទៀត ការតែងតាំង និងផ្ទេរភារកិច្ចនេះ គឺធ្វើឡើងស្របទៅនឹងគោលនយោបាយកែទម្រង់ស៊ីជម្រៅដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត បញ្ញាញាណ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និងជាការឆ្លើយតបទៅនឹងគោលនយោបាយកែទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជារបស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល ដោយផ្អែកលើអភិក្រម **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល"**។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជនផងដែរថា ការផ្ទេរភារកិច្ចនេះមិនមែនជាការដកហូតតំណែង ឬតួនាទីរបស់មន្ត្រីពន្ធដាររូបណាម្នាក់នោះទេ គឺគ្រាន់តែជាការកែសម្រួលភារកិច្ចរបស់មន្ត្រីពន្ធដារ ដើម្បីបង្កើនប្រសិទ្ធភាពការងារមន្ត្រីគ្រប់ៗរូប និងរបស់អគ្គនាយកដ្ឋានពន្ធដារ និងក្នុងន័យផ្លាស់ប្តូរនូវរបត់ការងារថ្មី ក្នុងគោលដៅប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានអស់លទ្ធភាព ស្របទៅនឹងកំណើនសេដ្ឋកិច្ចជាតិដែលរីកចម្រើនឥតឈប់ឈរ ដែលតម្រូវឱ្យមានការតែងតាំងនេះធ្វើឡើងជាចាំបាច់ដើម្បីជំនួសមន្ត្រីដែលចូលនិវត្តន៍ ឬដើម្បីបំពេញបន្ថែមតំណែងដែលនៅទំនេរតែប៉ុណ្ណោះ ហើយក៏មិនបានដកហូតតួនាទីមន្ត្រីរូបណាចេញពីមុខតំណែង ឬបញ្ឈប់ពីក្របខណ្ឌមន្ត្រីរាជការនោះដែរ។ ការតែងតាំងផ្ទេរភារកិច្ចនេះទៀតសោត មិនបានធ្វើឱ្យមន្ត្រីណាម្នាក់បាត់បង់តួនាទីភារកិច្ច និងមុខតំណែងរបស់ខ្លួនឡើយ គឺធ្វើឡើងប្រកបដោយតម្លាភាព និងឈរលើអភិក្រមនៃការអនុវត្តការងារ (Performance Bases) របស់មន្ត្រីម្នាក់ៗ ជាមូលដ្ឋានក្នុងការវាយតម្លៃ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥

**អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន
ពន្ធដារ